**មូលនិធិសន្តិភាពសាសាកាវ៉ា    មូលនិធិសាសាកាវ៉ាទូទាំងអាស៊ី**

ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០

# សេចក្តីប្រកាសពត៌មាន

ស្តីពី

**សមាជិកសភាកម្ពុជា៦រូបនឹងអញ្ជើញទៅប្រទេសជប៉ុន**
**ដើម្បីធ្វើទស្សនកិច្ចនៅសកលវិទ្យា ល័យអ៊ីស៊ីណុមីយ៉ា និង JAអ៊ីស៊ីណុមីយ៉ា**
**ទាក់ទងនឹងប្រធានបទការអភិវឌ្ឍន៏វិស័យកសិកម្ម**

មូលនិធិសាសាកាវ៉ាទូទាំងអាស៊ីនៃមូលនិធិសន្តិភាពសាសាកាវ៉ានៃប្រទេសជប៉ុន បានអញ្ជើញសមាជិកសភាចំរុះគណបក្សនយោបាយពីប្រទេសកម្ពុជា ៦រូប ទៅធ្វើទស្សនកិច្ចនៅប្រទេសជប៉ុន ពីថ្ងៃទី២៣ដល់ថ្ងៃទី៣០ ខែសីហាឆ្នាំ២០១០ខាងមុខនេះ។ នៅក្នុងដំណើរទស្សនកិច្ចនេះ គណៈប្រតិភូនឹងជួបពិភាក្សាជាមួយ អនុរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ និង សមាជិកសភាពីគណបក្សប្រឆាំងនិងគណបក្សគ្រប់គ្រងប្រទេសនៃប្រទេសជប៉ុន និង ស្វែងយល់អោយកាន់តែស៊ីជំរៅពីប្រវត្តិនៃការអភិវឌ្ឍន៏វិស័យកសិកម្ម និង ការអភិវឌ្ឍន៏បច្ចេកទេសដាំស្រូវនៅប្រទេសជប៉ុន។ ក្រៅពីនេះ ដើម្បីជាការចូលរួមចំនែកដល់ការអភិវឌ្ឍន៏វិស័យកសិកម្មនៅប្រទេសកម្ពុជាទៅថ្ងៃអនាគត គណៈប្រតិភូក៏នឹងធ្វើទស្សនកិច្ចនៅកសិដ្ឋានរបស់ ដេប៉ាតឺម៉ង់កសិកម្មនៃសកលវិទ្យាល័យអ៊ីស៊ីណុមីយ៉ា JA (Japan Agricultural Cooparatives) អ៊ីស៊ីណុមីយ៉ា និង ARI (Asian Rural Institute) នៃខេត្តអ៊ីស៊ីណុមីយ៉ា ពីថ្ងៃទី២៦ដល់ថ្ងៃ ទី២៨ខែសីហា។

គណៈប្រតិភូដែលនឹងអញ្ជើញទៅប្រទេសជប៉ុនមានសមាសភាពដូចខាងក្រោម :

១ **ឯកឧត្តម អាយ ខន** សមាជិកសភា និងជា ប្រធានគណៈប្រតិភូ (គណបក្សប្រជាជនកម្ពុជា)

២ **ឯកឧត្តម លី ណារុន** សមាជិកសភា និងជា អនុប្រធានគណៈប្រតិភូ (គណបក្សប្រជាជនកម្ពុជា)

៣ **ឯកឧត្តម ស៊ុក សំអេង** សមាជិកសភា (គណបក្សប្រជាជនកម្ពុជា)

៤ **លោកជំទាវ ដួង វណ្ណា** សមាជិកសភា (គណបក្សប្រជាជនកម្ពុជា)

៥　　**លោកជំទាវ ឯម ប៉ុណ្ណា** សមាជិកសភា　　(គណបក្សប្រជាជនកម្ពុជា)

៦　　**ឯកឧត្តម ជាម ច័ន្ទនី** សមាជិកសភា　　(គណបក្សសមរង្ស៊ី)

ការអញ្ជើញទៅទស្សនកិច្ចនៅប្រទេសជប៉ុនលើកនេះ គឺជាផ្នែកមួយនៃ "គំរោងផ្លាស់ប្តូរ រវាងសមាជិកសភាជប៉ុន និង សមាជិកសភានៃបណ្តាប្រទេសនៅអាស៊ី" ដោយផ្តោតទៅលើសមាជិកសភាវ័យក្មេង ដែលជាសរសរទ្រូងដ៏សំខាន់នៃបណ្តាប្រទេសនៅទ្វីបអាស៊ីដែលមិនសូវបានមកធ្វើទស្សនកិច្ចនៅប្រទេសជប៉ុន ដើម្បីផ្តល់នូវឱកាសចូលរួមកម្មសិក្សារយៈពេលខ្លីលើប្រធានបទអ្វីមួយ និង ទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធនានា ទាំងនៅក្នុងផ្នែកនយោបាយ និង រដ្ឋាភិបាល នៅប្រទេសជប៉ុន។ ចាប់តាំងពីឆ្នាំ២០០០មក មូលនិធិសន្តិភាពសាសាកាវ៉ាបានអញ្ជើញសមាជិកសភាប្រទេសកម្ពុជាអោយមកធ្វើទស្សនកិច្ចនៅប្រទេសជប៉ុន មានចំនួនសរុបជិត ៥០រូបមកហើយ។

ពត៌មានបន្ថែម សូមទំនាក់ទំនងៈ

ឃី សោភ័ណ

មូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា

The iCON Professional Building ជាន់ទី៣

២១៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ

ទូរស័ព្ទ-ទូរសារ : +855-23-216-434

អ៊ីមេល : k-sophoin@ciesf.org

*មូលនិធិសន្តិភាពសាសាកាវ៉ា គឺជា មូលនិធិដែលបង្កើតឡើងក្នុងគោលបំណងទ្រទ្រង់សង្គមស៊ីវិល ដែលធ្វើសកម្មភាពបំរើសុខមាលភាពមនុស្សជាតិជាលក្ខណៈអន្តរជាតិ ដោយឈរលើចក្ខុវិស័យសកល។ មូលនិធិសាសាកាវ៉ាទូទាំងអាស៊ី គឺជា មូលនិធិមួយនៅក្នុងមូលនិធិសន្តិភាពសាសាកាវ៉ា ដែលផ្តោតទៅលើ ការងារអភិវឌ្ឍន៍ធនធានមនុស្ស និង ការផ្លាស់ប្តូរសមាជិកនៃស្ថាប័ននានានៃប្រទេសក្នុងតំបន់អាស៊ី ក្នុងគោលបំណងដោះស្រាយបញ្ហាទាក់ទងនឹងការរួបរួមតំបន់ និង ស្ថេរភាពនិងវឌ្ឍនភាពនៅក្នុងតំបន់។*

---

* មូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា គឺជា ការិយាល័យទំនាក់ទំនងរបស់មូលនិធិសន្តិភាពសាសាកាវ៉ាប្រចាំប្រទេសកម្ពុជា។